**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

លេខ ១១៧៣ សជណ.កសក

**សេចក្តីជូនដំណឹង**

**ស្តីពី**

**ការទប់ស្កាត់ការធ្វើនេសាទឈ្នាងអូសលៀស ឬខ្នៅរូមផ្សំដោយកម្លាំងម៉ាស៊ីន**

កន្លងមកថ្មីៗនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសង្កេតឃើញថាមានសកម្មភាពធ្វើនេសាទដោយឧបករណ៍នេសាទឈ្នាងអូសលៀសឬខ្នៅនៅបឹងទន្លេសាបរួមផ្សំដោយកម្លាំងម៉ាស៊ីនគ្មានការអនុញ្ញាតកំពុងរីករាលដាលយ៉ាងខ្លាំងបង្កឱ្យប៉ះពាល់ដល់វារីសត្វ រុក្ខជាតិស្រទាប់បាត និងប្រព័ន្ធអេកូឡូស៊ីជលផលយ៉ាងធ្ងន់ធ្ងរ។ ដូច្នេះដើម្បីចៀសវាងនូវផលប៉ះពាល់ធ្ងន់ធ្ងរនេះ សូមបងប្អូនប្រជានេសាទដែលបាននិងកំពុងប្រើឧបករណ៍នេសាទឈ្នាងអូសលៀសឬខ្នៅរួមផ្សំដោយកម្លាំងម៉ាស៊ីននៅតំបន់បឹងទន្លេសាបត្រូវបញ្ឈប់សកម្មភាពជាបន្ទាន់ លើកលែងតែការធ្វើនេសាទជាលក្ខណៈគ្រួសារដោយពុំប្រើកម្លាំងម៉ាស៊ីនរួមផ្សំ។ ក្នុងករណីមិនបញ្ឈប់សកម្មភាពល្មើស ជនល្មើសនឹងត្រូវទទួលទោសតាមច្បាប់ស្តីពីជលផល ដូចមានក្នុងមាត្រា៩៤ ដែលបានចែងថា ត្រូវទទួលពិន័យអន្តរការណ៍ពីរដ្ឋបាលជលផលជាប្រាក់ពីមួយដងទៅពីរដងលើតម្លៃទីផ្សារនៃវត្ថុតាងពិតប្រាកដ ឯវត្ថុតាងទាំងអស់ត្រូវប្រគល់ឱ្យសាមីជនវិញ។ ដោយឡែក ជនណាប្រព្រឹត្តបទល្មើសចាប់ពីពីរដងឡើងទៅឬនៅពេលយប់ ត្រូវទទួលពិន័យអន្តរការណ៍ពីរដ្ឋបាលជលផលទ្វេដងនៃប្រាក់ពិន័យវត្ថុតាងពិតប្រាកដ ឯវត្ថុតាងទាំងអស់ត្រូវរឹបអូសជាសម្បត្តិរដ្ឋ។

មន្ត្រីរដ្ឋបាលជលផលត្រូវសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធនិងរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីចាត់វិធានការទប់ស្កាត់និងបង្ក្រាបបទល្មើសនេះឱ្យបានតឹងរ៉ឹងនិងម៉ឺងម៉ាត់បំផុត។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សង្ឃឹមយ៉ាងមុតមាំថា ប្រជានេសាទដែលប្រើឧបករណ៍នេសាទឈ្នាងអូសលៀសឬខ្នៅ រួមផ្សំដោយកម្លាំងម៉ាស៊ីននៅតំបន់បឹងទន្លេសាបទាំងអស់នឹងបញ្ឈប់សកម្មភាពតាមការជូនដំណឹងនេះប្រកបដោយមនសិការខ្ពស់ ដើម្បីរួមចំណែកថែរក្សា ការពារធនធានជលផលឱ្យមាននិរន្តរភាពសម្រាប់កូនចៅជំនាន់ក្រោយៗទៀត។

ថ្ងៃ ពុធ ១៤កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល:**

- ក្រសួងមហាផ្ទៃ
- រដ្ឋបាលខេត្តជុំវិញបឹងទន្លេសាប
  "ដើម្បីជូនជ្រាប និងសហការអនុវត្ត"
- រដ្ឋបាលជលផល
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តជុំវិញបឹងទន្លេសាប
  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- ឯកសារ កាលប្បវត្តិ

Scanned with CamScanner

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23 217 320